# បទបញ្ជា
# ស្តីពី
# របបសន្តិសុខសង្គមផ្នែកប្រាក់សោធន

# មាតិកា

១.គោលទូទៅនៃរបបសន្តិសុខសង្គម
២.ស្ថាប័នមានសមត្ថកិច្ច និងការចុះបញ្ជីសហគ្រាសគ្រឹះស្ថាន និងកម្មករនិយោជិត
៣.វិសាលភាព
៤.តាវកាលិកផ្នែកប្រាក់សោធនតាមរបបភាគទាន
៥.លក្ខខណ្ឌនិងតាវកាលិកសោធនជរាភាព
៦.លក្ខខណ្ឌនិងតាវកាលិកវិភាជន៍ជរាភាព
៧.លក្ខខណ្ឌ និងតាវកាលិកសោធនទុព្វលភាព
៨.សោធនឧត្តរជីវី
៩.លក្ខខណ្ឌនិងសិទ្ធិនៃការចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត
១០.សោធនជរាភាពតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ
១១.លក្ខខណ្ឌទទួលបានសោធនជរាភាពអយ្យកប្បញ្ញត្តិ
១២.ភាគទានផ្នែកប្រាក់សោធន
១៣.ការតំឡើងអត្រាភាគទាន

# ១.គោលការណ៍ទូទៅនៃរបបសន្តិសុខសង្គម



# ២.ស្ថាប័នមានសមត្ថកិច្ច

| បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) | |
|---|---|
| **ប.ស.ស.** ជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម។ | **ប.ស.ស.** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលត្រូវបានបង្កើតដោយព្រះរាជក្រឹត្យនស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ |

# ២.១.ការចុះបញ្ជីសហគ្រាសគ្រឹះស្ថាននិងកម្មករនិយោជិតពេលរបបប្រាក់សោធនចាប់ផ្តើមដំណើរការ

សហគ្រាសបានចុះបញ្ជីរួចនៅប.ស.ស. ផ្នែកហានិភ័យនិងថែទាំសុខភាព(ក)

+

កម្មករនិយោជិតកំពុងបម្រើការងារក្នុងសហគ្រាស(ក)

=

ជាសមាជិកផ្នែកប្រាក់សោធនដោយស្វ័យប្រវត្ត

# ២.២.សហគ្រាសគ្រឹះស្ថានមិនទាន់ចុះបញ្ជីនៅប.ស.ស.

សហគ្រាសគ្រឹះស្ថានមិនទាន់បានចុះបញ្ជីនៅប.ស.ស.

| សហគ្រាសគ្រឹះស្ថាន | កម្មករនិយោជិតកំពុងបម្រើការងារ |
|---|---|

↓

មានរយៈពេល៣០ថ្ងៃចុះបញ្ជីក្រោយអនុក្រឹត្យផ្នែកប្រាក់សោធនចូលធរមាន

↓

ជាសមាជិកផ្នែកប្រាក់សោធន

# ៣.វិសាលភាព

## វិសាលភាព

- បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈលើកលែង
  - មន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ (លើកលែងតែផ្នែកប្រាក់សោធន)
  - មន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារ(ផ្តល់តែតាវកាលិកផ្នែកព្យាបាលនិងថែទាំសុខភាព)
- បុគ្គលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ
- បុគ្គលស្វ័យនិយោជន៍

# ៤.ការកាលិកផ្នែកប្រាក់សោធនតាមរបបភាគទាន

ការកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ចនិងតាមរបបភាគទានស្ម័គ្រចិត្ត រួមមាន

- សោធនជរាភាព
- សោធនទុព្វលភាព
- សោធនឧត្តរជីវី
- វិភាជន៍បូជាសព

# ៥.លក្ខខណ្ឌ និងតាវការលិកសោធនជរាភាព



# ៥.១.រូបមន្តសោធនជរាភាព

**សជ = អស x បឈម**

**ស.ជ** — ជាសោធនជរាភាពរបស់សាមីជនដែលត្រូវទទួលបាន

**អ.ស** — ជាអត្រាសោធនដែលត្រូវទទួលបាន

**បឈម** — ជាប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមី

- **បឈម** (ប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទាន) សំដៅដល់ផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈពេលមិនលើស១២០ខែចុងក្រោយមុនកាលបរិច្ឆេទមានសិទ្ធិទាមទារតាវកាលិក។

$$\textbf{បឈម} = \frac{\text{ប្រាក់ឈ្នួលជាប់ភាគទានដែលបានប្រកាសមកប.ស.ស.ចុងក្រោយចំនួន១២០ខែ}}{\text{១២០ខែ}}$$

- **ឆ្នាំភាគទាន** សំដៅដល់ចំនួនឆ្នាំដែលសមាជិក**ប.ស.ស**.បានបង់ភាគទានក្នុងផ្នែកប្រាក់សោធន។

**ឆ្នាំភាគទាន** យកចំនួនខែដែលសាមីជនបានបង់ភាគទានផ្នែកប្រាក់សោធន(ក)ចែកនឹង១២ខែ។

$$\textbf{ឆ្នាំភាគទាន} = \frac{\text{(ក)}}{\text{១២ខែ}}$$

**សម្គាល់:** ផលចែកនៃ**ឆ្នាំភាគទាន** បើសំណល់លើស៦ខែ ត្រូវបូកថែម១ឆ្នាំ

បើសំណល់ត្រឹម៦ខែចុះ ត្រូវរក្សាចំនួនឆ្នាំដដែល។

ឧទាហរណ៍ បើគណនាឃើញ២០ឆ្នាំ៨ខែ **ឆ្នាំភាគទាន** ត្រូវស្មើ២១ឆ្នាំ(សំណល់លើស៦ខែ ត្រូវបូកថែម១ឆ្នាំ)

បើគណនាឃើញបើ២០ឆ្នាំ៦ខែ **ឆ្នាំភាគទាន** ត្រូវស្មើ២០ឆ្នាំ(សំណល់ត្រឹម៦ខែចុះ ត្រូវរក្សាចំនួនឆ្នាំដដែល)។

# ៥.២.ការគណនា

លោកស្រី នីតា មានអាយុ២៥ឆ្នាំ បានបង់ភាគទានចូល **ប.ស.ស**. ផ្នែកប្រាក់សោធនរយៈពេល២៥០ខែ(២០ឆ្នាំ៨ខែ)

**សជ** = **អស** x **បឈម**

ប្រាក់ឈ្នួលជាប់ភាគទាន(យក១២០ខែចុងក្រោយមុនចូលនិវត្តន៍) ប្រាក់ឈ្នួលជាប់ភាគទាន=១,១០០,០០០រៀលចំនួន៣០ខែ

១,១៥០,០០០រៀលចំនួន៥០ខែ

១,២០០,០០០រៀលចំនួន៤០ខែ

$$\textbf{បឈម} = \frac{១,១០០,០០០(៣០ខែ)+១,១៥០,០០០(៥០ខែ)+១,២០០,០០០(៤០ខែ)}{១២០ខែ} = ១,១៥៤,២០០\text{រៀល}$$

$$\textbf{អស} = \frac{២៥០ខែ}{១២ខែ} = ២០\text{ឆ្នាំ }៨\text{ខែ}$$

=២១ឆ្នាំ(មានចែងក្នុងតារាង៖បសម្ព័ន្ធនៃអនុក្រឹត្យ)

**សជ** = **អស** x **បឈម**

=**២១ឆ្នាំ** x**១,១៥៤,២០០រៀល**

= **៣៣.៧៥%** x**១,១៥៤,២០០រៀល**

=**៣៨៩,៥៤២រៀល**

## ឧបសម្ព័ន្ធ

| ឆ្នាំ | អត្រាសោធន | រូបមន្ត |
|---|---|---|
| ១ | ១,៧៥% | ១×១,៧៥% |
| ២ | ៣,៥០% | ២×១,៧៥% |
| ៣ | ៥,២៥% | ៣×១,៧៥% |
| ៤ | ៧,០០% | ៤×១,៧៥% |
| ៥ | ៨,៧៥% | ៥×១,៧៥% |
| ៦ | ១០,៥០% | ៦×១,៧៥% |
| ៧ | ១២,២៥% | ៧×១,៧៥% |
| ៨ | ១៤,០០% | ៨×១,៧៥% |
| ៩ | ១៥,៧៥% | ៩×១,៧៥% |
| ១០ | ១៧,៥០% | ១០×១,៧៥% |
| ១១ | ១៩,២៥% | ១១×១,៧៥% |
| ១២ | ២១,០០% | ១២×១,៧៥% |
| ១៣ | ២២,៧៥% | ១៣×១,៧៥% |
| ១៤ | ២៤,៥០% | ១៤×១,៧៥% |
| ១៥ | ២៦,២៥% | ១៥×១,៧៥% |
| ១៦ | ២៧,៥០% | ១៥×១,៧៥%+១×១,២៥% |
| ១៧ | ២៨,៧៥% | ១៥×១,៧៥%+២×១,២៥% |
| ១៨ | ៣០,០០% | ១៥×១,៧៥%+៣×១,២៥% |
| ១៩ | ៣១,២៥% | ១៥×១,៧៥%+៤×១,២៥% |
| ២០ | ៣២,៥០% | ១៥×១,៧៥%+៥×១,២៥% |
| ២១ | ៣៣,៧៥% | ១៥×១,៧៥%+៦×១,២៥% |
| ២២ | ៣៥,០០% | ១៥×១,៧៥%+៧×១,២៥% |
| ២៣ | ៣៦,២៥% | ១៥×១,៧៥%+៨×១,២៥% |
| ២៤ | ៣៧,៥០% | ១៥×១,៧៥%+៩×១,២៥% |
| ២៥ | ៣៨,៧៥% | ១៥×១,៧៥%+១០×១,២៥% |
| ២៦ | ៤០,០០% | ១៥×១,៧៥%+១១×១,២៥% |
| ២៧ | ៤១,២៥% | ១៥×១,៧៥%+១២×១,២៥% |
| ២៨ | ៤២,៥០% | ១៥×១,៧៥%+១៣×១,២៥% |
| ២៩ | ៤៣,៧៥% | ១៥×១,៧៥%+១៤×១,២៥% |
| ៣០ | ៤៥,០០% | ១៥×១,៧៥%+១៥×១,២៥% |
| ៣១ | ៤៦,២៥% | ១៥×១,៧៥%+១៦×១,២៥% |
| ៣២ | ៤៧,៥០% | ១៥×១,៧៥%+១៧×១,២៥% |
| ៣៣ | ៤៨,៧៥% | ១៥×១,៧៥%+១៨×១,២៥% |
| ៣៤ | ៥០,០០% | ១៥×១,៧៥%+១៩×១,២៥% |
| ៣៥ | ៥១,២៥% | ១៥×១,៧៥%+២០×១,២៥% |
| ៣៦ | ៥២,៥០% | ១៥×១,៧៥%+២១×១,២៥% |
| ៣៧ | ៥៣,៧៥% | ១៥×១,៧៥%+២២×១,២៥% |
| ៣៨ | ៥៥,០០% | ១៥×១,៧៥%+២៣×១,២៥% |
| ៣៩ | ៥៦,២៥% | ១៥×១,៧៥%+២៤×១,២៥% |
| ៤០ | ៥៧,៥០% | ១៥×១,៧៥%+២៥×១,២៥% |
| ៤១ | ៥៨,៧៥% | ១៥×១,៧៥%+២៦×១,២៥% |
| ៤២ | ៦០,០០% | ១៥×១,៧៥%+២៧×១,២៥% |
| ៤៣ | ៦១,២៥% | ១៥×១,៧៥%+២៨×១,២៥% |
| ៤៤ | ៦២,៥០% | ១៥×១,៧៥%+២៩×១,២៥% |
| ៤៥ | ៦៣,៧៥% | ១៥×១,៧៥%+៣០×១,២៥% |
| ៤៦ | ៦៥,០០% | ១៥×១,៧៥%+៣១×១,២៥% |
| ៤៧ | ៦៦,២៥% | ១៥×១,៧៥%+៣២×១,២៥% |
| ៤៨ | ៦៧,៥០% | ១៥×១,៧៥%+៣៣×១,២៥% |
| ៤៩ | ៦៨,៧៥% | ១៥×១,៧៥%+៣៤×១,២៥% |
| ៥០ | ៧០,០០% | ១៥×១,៧៥%+៣៥×១,២៥% |

* អត្រាសមាច័យ ១,៧៥% នៃ ១៥ឆ្នាំភាគទានដំបូង
* អត្រាសមាច័យ ១,២៥% នៃឆ្នាំភាគទានបន្តបន្ទាប់

# ៦.លក្ខខណ្ឌ និងតាវការលិកវិភាជន៍ជរាភាព



# ៦.១.រូបមន្តវិភាជន៍ជរាភាព

**ទភជ** ជាវិភាជន៍ជរាភាពរបស់សាមីជនដែលត្រូវទទួលបាន

**ទភជ = ផភ (១+ សផ)**

**ផភ** ជាផលបូកចំនួនភាគទានដែលបានបង់សម្រាប់របបប្រាក់សោធន

**សផ** ជាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ផ្លូវការ

# ៦.២.ការគណនា

លោក តារា ជាសមាជិកសោធន គាត់បង់ភាគទានបានចំនួន១០ខែ។គាត់បានឈប់បង់រហូត។ប្រាក់ឈ្នួលរបស់គាត់ជាប្រចាំខែ១,២០០,០០០៛។

ភាគទានត្រូវបង់៤%មានន័យថា ៖

កម្មករនិយោជិត២%នៃ១,២០០,០០០៛ស្មើ២៤,០០០៛

និយោជក២%នៃ១,២០០,០០០៛ស្មើ២៤,០០០៛។

ជាសរុបភាគទានដែលបានបង់សរុបក្នុងមួយខែ៤៨,០០០៛។

ដូចនេះ៖ ផភ គឺយកចំនួនភាគទានប្រចាំខែគុណនឹងចំនួនដែលខែដែលបានបង់។

**ផភ** =៤៨,០០០រៀល(២៤,០០០៛ + ២៤,០០០៛)X១០ខែ

**ទភជ = ផភ (១+ សផ)**

ជាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ផ្លូវការ ២%

**ទភជ**=៤៨០,០០០៛ (១+២%)
=៤៨០,០០០៛( ១ +២/១០០)
=៤៨៩,៦០០៛

# ៧.លក្ខខណ្ឌនិងតាវកាលិកសោធនទុព្វលភាព



# ៧.១.រូបមន្តសោធនទុព្វលភាព

សទ =អស X បឈម

ស.ទ

ជាសោធនទុព្វលភាពរបស់សាមីជនដែលត្រូវទទួលបាន

អ.ស

ជាអត្រាសោធនដែលត្រូវទទួលបាន

បឈម

ជាប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីខ្លួន

# ៧.២.ការគណនា

លោក សុភា មានអាយុ 28 ឆ្នាំបានបង់ភាគទានចូលរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនរយៈពេល 7 ឆ្នាំ ប៉ុន្តែជាអកុសលគាត់ក៏មានជំងឺធ្វើការលែងកើត (ធ្លាក់ខ្លួនទុព្វលភាព)។ **បឈម** 1,000,000 ៛

**អ.ស រយៈពេលបង់7ឆ្នាំ**

7 ឆ្នាំ = 12,25%

រយៈពេលបង់ភាគទានតិចជាង៣០ឆ្នាំ

កម្រិតអប្បបរមានៃសោធនទុព្វលភាពត្រូវកំណត់ស្មើនឹង ៤៥% (សែសិបប្រាំភាគរយ) នៃប្រាក់ឈ្នួលមធ្យមបង់ភាគទានរបស់សាមីជន។

**បឈម** = 1,000,000 ៛

**សទ** =**អស** X **បឈម**

**សទ** = 45% x 1,000,000 ៛ = 450,000 ៛

**អស**( **អត្រាសោធន** = 45% )

## ឧបសម្ព័ន្ធ

| ឆ្នាំ | អត្រាសោធន | រូបមន្ត |
|---|---|---|
| ១ | ១,៧៥% | ១×១,៧៥% |
| ២ | ៣,៥០% | ២×១,៧៥% |
| ៣ | ៥,២៥% | ៣×១,៧៥% |
| ៤ | ៧,០០% | ៤×១,៧៥% |
| ៥ | ៨,៧៥% | ៥×១,៧៥% |
| ៦ | ១០,៥០% | ៦×១,៧៥% |
| ៧ | ១២,២៥% | ៧×១,៧៥% |
| ៨ | ១៤,០០% | ៨×១,៧៥% |
| ៩ | ១៥,៧៥% | ៩×១,៧៥% |
| ១០ | ១៧,៥០% | ១០×១,៧៥% |
| ១១ | ១៩,២៥% | ១១×១,៧៥% |
| ១២ | ២១,០០% | ១២×១,៧៥% |
| ១៣ | ២២,៧៥% | ១៣×១,៧៥% |
| ១៤ | ២៤,៥០% | ១៤×១,៧៥% |
| ១៥ | ២៦,២៥% | ១៥×១,៧៥% |
| ១៦ | ២៧,៥០% | ១៥×១,៧៥%+១×១,២៥% |
| ១៧ | ២៨,៧៥% | ១៥×១,៧៥%+២×១,២៥% |
| ១៨ | ៣០,០០% | ១៥×១,៧៥%+៣×១,២៥% |
| ១៩ | ៣១,២៥% | ១៥×១,៧៥%+៤×១,២៥% |
| ២០ | ៣២,៥០% | ១៥×១,៧៥%+៥×១,២៥% |
| ២១ | ៣៣,៧៥% | ១៥×១,៧៥%+៦×១,២៥% |
| ២២ | ៣៥,០០% | ១៥×១,៧៥%+៧×១,២៥% |
| ២៣ | ៣៦,២៥% | ១៥×១,៧៥%+៨×១,២៥% |
| ២៤ | ៣៧,៥០% | ១៥×១,៧៥%+៩×១,២៥% |
| ២៥ | ៣៨,៧៥% | ១៥×១,៧៥%+១០×១,២៥% |
| ២៦ | ៤០,០០% | ១៥×១,៧៥%+១១×១,២៥% |
| ២៧ | ៤១,២៥% | ១៥×១,៧៥%+១២×១,២៥% |
| ២៨ | ៤២,៥០% | ១៥×១,៧៥%+១៣×១,២៥% |
| ២៩ | ៤៣,៧៥% | ១៥×១,៧៥%+១៤×១,២៥% |
| ៣០ | ៤៥,០០% | ១៥×១,៧៥%+១៥×១,២៥% |
| ៣១ | ៤៦,២៥% | ១៥×១,៧៥%+១៦×១,២៥% |
| ៣២ | ៤៧,៥០% | ១៥×១,៧៥%+១៧×១,២៥% |
| ៣៣ | ៤៨,៧៥% | ១៥×១,៧៥%+១៨×១,២៥% |
| ៣៤ | ៥០,០០% | ១៥×១,៧៥%+១៩×១,២៥% |
| ៣៥ | ៥១,២៥% | ១៥×១,៧៥%+២០×១,២៥% |
| ៣៦ | ៥២,៥០% | ១៥×១,៧៥%+២១×១,២៥% |
| ៣៧ | ៥៣,៧៥% | ១៥×១,៧៥%+២២×១,២៥% |
| ៣៨ | ៥៥,០០% | ១៥×១,៧៥%+២៣×១,២៥% |
| ៣៩ | ៥៦,២៥% | ១៥×១,៧៥%+២៤×១,២៥% |
| ៤០ | ៥៧,៥០% | ១៥×១,៧៥%+២៥×១,២៥% |
| ៤១ | ៥៨,៧៥% | ១៥×១,៧៥%+២៦×១,២៥% |
| ៤២ | ៦០,០០% | ១៥×១,៧៥%+២៧×១,២៥% |
| ៤៣ | ៦១,២៥% | ១៥×១,៧៥%+២៨×១,២៥% |
| ៤៤ | ៦២,៥០% | ១៥×១,៧៥%+២៩×១,២៥% |
| ៤៥ | ៦៣,៧៥% | ១៥×១,៧៥%+៣០×១,២៥% |
| ៤៦ | ៦៥,០០% | ១៥×១,៧៥%+៣១×១,២៥% |
| ៤៧ | ៦៦,២៥% | ១៥×១,៧៥%+៣២×១,២៥% |
| ៤៨ | ៦៧,៥០% | ១៥×១,៧៥%+៣៣×១,២៥% |
| ៤៩ | ៦៨,៧៥% | ១៥×១,៧៥%+៣៤×១,២៥% |
| ៥០ | ៧០,០០% | ១៥×១,៧៥%+៣៥×១,២៥% |

* អត្រាសមាច័យ ១,៧៥% នៃ ១៥ឆ្នាំភាគទានដំបូង
* អត្រាសមាច័យ ១,២៥% នៃឆ្នាំភាគទានបន្តបន្ទាប់

# ៨.សោធនឧត្តរជីវី



សោធនិក ជរាភាព
សមាជិកបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច ៦០ខែ
សោធនិក ទុព្វលភាព
វិភាជន៍បូជាសព
សោធនឧត្តរជីវី
សិទ្ធិវន្តនៃសោធនឧត្តរជីវី
ទឹកប្រាក់ចំនួន.......
ភ្ជាប់សេចក្តីចម្លងមរណៈភាព
ចុះពិនិត្យផ្ទាល់
ដោយ**ប.ស.ស.**

# ៨.១.សិទ្ធិទទួលសោធននិវត្តន៍ជីវិត

| សហព័ទ្ធ(ប្តីឬប្រពន្ធ) | កូន |
| --- | --- |
| • មានសំបុត្រអាពាហ៍ពិពាហ៍<br>• មិនមានប្រកបការងារឬមុខរបរមានប្រាក់ចំណូលលើបន្ទាត់ភាពក្រីក្រ | • មិនទាន់រៀបអាពាហ៍ពិពាហ៍<br>• មានអាយុមិនលើស១៨ឆ្នាំ បើកូនពិការឬមានជំងឺរ៉ាំរ៉ៃ ផ្តល់ជូនអស់មួយជីវិត<br>• មិនមានប្រកបការងារឬមុខរបរមានប្រាក់ចំណូលលើបន្ទាត់ភាពក្រីក្រ |

# ៨.២.ការបែងចែកប្រាក់សោធនិកជូនសិទ្ធិវន្ត

**៩៥%នៃប្រាក់សោធនិក**

- ប្តីឬប្រពន្ធ ទទួលបានពាក់កណ្តាល នៃប្រាក់៩៥%នៃប្រាក់សោធនិក
- កូន ទទួលបានពាក់កណ្តាលនៃប្រាក់៩៥%នៃប្រាក់សោធនិក

**មានតែសហព័ទ្ធឬកូន**

- ទទួលបាន១០០%នៃប្រាក់៩៥%នៃប្រាក់សោធនិក

**កូនមានជំងឺរ៉ាំរ៉ៃឬពិការ**

- ទទួលបានចំណែកនៃប្រាក់សោធនិក អស់មួយជីវិត

# ៨.៣.ការផុតរលត់នៃសិទ្ធិវន្តនៃសោធនឧត្តរជីវី

សិទ្ធិទទួលបានសោធនឧត្តរត្រូវ**ផុតរលត់**ក្នុងស្ថានភាពដូចខាងក្រោម:

- សិទ្ធិវន្តទទួលមរណភាព
- សហព័ទ្ធរៀបការជាថ្មីស្របតាមនីតិវិធីច្បាប់ៗសាមីជនត្រូវជូនដំណឹងមក **ប.ស.ស**.យ៉ាងយូរ៣០ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការរៀបការថ្មី

# ៩.លក្ខខណ្ឌនិងសិទ្ធិនៃការចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត

សមាជិកអាចចូលរួមផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តបាន លុះត្រាតែស្ថិតក្នុងស្ថានភាពចំនួន៣ដូចខាងក្រោម៖

១.បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធនរួច (បានបង់ភាគទានយ៉ាងតិច៦ខែ)

២.បានបាត់បង់ការងារដែលមានប្រាក់ឈ្នួលមុនអាយុ៦០ឆ្នាំ

៣.និងមានលទ្ធភាពបង់ភាគទានបន្ត

១.បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធនរួច (បានបង់ភាគទានយ៉ាងតិច៦ខែ)

២.មានអាយុ៦០ឆ្នាំ

៣.និងមានលទ្ធភាពបង់ភាគទានបន្ត

១.បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន

២.កំពុងធ្វើការ

៣.ប្រាក់ឈ្នួលខ្ពស់ជាងប្រាក់ឈ្នួលពិដាន (តាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ)

# ៩.១.មូលដ្ឋានភាគទានសម្រាប់ការបង់ផ្នែកប្រាក់សោធន ដោយស្ម័គ្រចិត្ត

សមាជិកផ្នែកប្រាក់សោធនដែលបានបាត់បង់ការងារមុនអាយុ៦០ឆ្នាំ

សមាជិកផ្នែកប្រាក់សោធនដែលមានអាយុចាប់ពី៦០ឆ្នាំ ហើយនៅចង់បង់បន្ត

ការបង់ភាគទានស្ម័គ្រចិត្តគឺយកប្រាក់ឈ្នួលជាប់ភាគទាន៦ខែចុងក្រោយមុនបាត់បង់ការងារ ឬដល់អាយុ៦០ឆ្នាំជាមូលដ្ឋានសម្រាប់បង់ភាគទាន

# ៩.២.តាវកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត

- សោធនជរាភាពឬ សោធនទុព្វលភាព
- វិភាជន៍បូជាសព(ករណីសមាជិកបង់ភាគទានបានយ៉ាងតិច៦០ខែ
- សោធនឧត្តរជីវី

# ១០.សោធនជរាភាពតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ

| សោធនជរាភាពតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ | | |
|---|---|---|
| ១.ចុះបញ្ជីក្នុងផ្នែកប្រាក់សោធន | ២.កំពុងធ្វើការ | ៣.ប្រាក់ឈ្នួលខ្ពស់ជាប្រាក់ឈ្នួលពិតាន (ប្រាក់ឈ្នួលពិតានកំណត់ដោយ ប.ស.ស.ត្រឹម១,២០០,០០០រៀល) |

# ១០.១.សោធនជរាភាពតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ

**សជ = បស / ចរខ**

- **សជ** គឺជាសោធនជរាភាពរបស់សាមីជនដែលត្រូវទទួលបាន
- **បស** គឺជាប្រាក់ដែលនៅសល់២/៣ នៃចំនួនប្រាក់ភាគទានដែលបានបង់សរុប ដោយបូកនឹងផលនៃការវិនិយោគ
- **ចរខ** គឺជាចំនួនខែដែលសាមីជនរំពឹងរស់បានក្រោយអាយុចូលនិវត្តន៍
- **ចរខ** =(អយ-អច) x ១២
- **អយ** គឺជាអាយុរំពឹងទុក(ចេញដោយក្រសួងផែនការ)
- **អច** គឺជាអាយុចូលនិវត្តន៍ដែលកំណត់ដោយច្បាប់

## ១០.២.
ឧទារ អ្នកស្រី នីតា គាត់បានបង់ភាគទានស្ម័គ្រចិត្ត ជាសរុបទឹកប្រាក់ភាគទានបាន៨លាន តែបូកទាំងផលវិនិយោគ គាត់បានសរុប៩លានរៀល។

**សជ = បស / ចរខ**

**=៦,000,000៛/១២0ខែ**

**=៥0,000៛**

- ចំនួនភាគទានដែលបានបង់សរុបរួមទាំងផលវិនិយោគ**៩លានរៀល**
- **បស** គឺជាប្រាក់ដែលនៅសល់២/៣ នៃចំនួនប្រាក់ភាគទានដែលបង់សរុប ដោយបូកនឹងផលនៃការវិនិយោគ គឺមានចំនួន **៦លានរៀល**
- **ចរខ គឺជា**ចំនួនខែដែលសាមីជនរំពឹងរស់បានក្រោយអាយុចូលនិវត្តន៍
- **អយ** គឺជាអាយុរំពឹងទុក **៧0ឆ្នាំ**(**តាមក្រសួងផែនការ**)
- **អច** គឺជាអាយុចូលនិវត្តន៍ដែលកំណត់ដោយច្បាប់**៦0ឆ្នាំ**
- **ចរខ=** (អយ-អច) x ១២ = (៧0ឆ្នាំ-៦0ឆ្នាំ) x ១២=**១២0ខែ**

កំពុងទទួលបានប្រាក់នេះ(សជ)បានចំនួន៨ខែ រួចមកគាត់ទទួលមរណៈភាព ដូចនេះចំនួនខែដែលនៅសល់ចំនួន ១១៦ខែគឺត្រូវបើកផ្តាច់ជូនសន្តតិជនដែលសោធនិកបានជ្រើសរើសរួច។

# ១១.លក្ខខណ្ឌទទួលបានសោធនជរាភាពអយ្យកប្បញ្ញត្តិ

## សោធនជរាភាពអយ្យកប្បញ្ញត្តិ

- ចុះបញ្ជីផ្នែកប្រាក់សោធន
- មានអាយុលើស៣០ឆ្នាំ
- បានបង់ភាគទានយ៉ាងតិច២៤ខែក្នុងរយៈពេល៣៦ខែគិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការផ្នែកប្រាក់សោធន

# ១១.១.រូបមន្តសោធនជរាភាពអយ្យកប្បញ្ញត្តិ

**សជអ** = **អស** x **បឈម**

- **សជអ** ជាសោធនជរាភាពអយ្យកប្បញ្ញត្តិរបស់សាមីជនដែលត្រូវទទួលបាន
- **អស** = ឆក+អប

  អប = ( អសប- ៣០)/២
- **បឈម** ជាប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីខ្លួន
- អស ជាអត្រាសោធនដែលត្រូវទទួលបានដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១ នៃអនុក្រឹត្យនេះ
- ឆក ជាចំនួនឆ្នាំដែលបានបង់ភាគទាន
- អប ជាចំនួនឆ្នាំដែលត្រូវបន្ថែមសម្រាប់សោធនអយ្យកប្បញ្ញត្តិ
- អសប ជាអាយុរបស់សមាជិក ប.ស.ស. ដែលចូលបម្រើការងារដំបូងគិតចាប់ពីកាលបរិច្ឆេទដំណើរការដំបូងនៃផ្នែកប្រាក់សោធន

## ១១.២.ការគណនា

នៅពេលផ្ទែកប្រាក់សោធនចាប់ផ្ដើមដំណើរការ លោកស្រី សុភាមានអាយុ 40 ឆ្នាំហើយគាត់បានបង់ភាគទានចូលបេឡាជាតិសន្តិសុខសង្គមផ្នែកប្រាក់សោធនរយៈពេល 20 ឆ្នាំបន្តបន្ទាប់។ **បឈម** 1,085,400 ៛

**សជអ** = **អស** x **បឈម**

**អស** = ឆក+អប

= 20ឆ្នាំ(ចំនួនឆ្នាំបង់ភាគទាន)+អប

អប = (អសប- 30)/2

= (40ឆ្នាំ -30)/2

= 5ឆ្នាំ

**អស** = ឆក+អប

= 20ឆ្នាំ +5ឆ្នាំ

**អស** = 20+5 ឆ្នាំ = 38.75% (មើលតាមតារាង)

**សជអ** = 38.75% x 1,085,400 = 420,600 ៛

# ១២.ភាគទានផ្នែកប្រាក់សោធន

ការបង់ភាគទានផ្នែកប្រាក់សោធនក្នុងរបប
ភាគទានជាកាតព្វកិច្ច ត្រូវមានការចូលរួម
រវាង**និយោជក និងកម្មករនិយោជិត**

ការបង់ភាគទានផ្នែកប្រាក់សោធនក្នុងរបប
ភាគទានស្ម័គ្រចិត្ត ជាបន្ទុកដោយផ្ទាល់របស់
**កម្មករនិយោជិត**

# ១៣.ការតំឡើងអត្រាភាគទាន

| ៥ឆ្នាំចាប់ពីអនុវត្ត | ៥ឆ្នាំបន្ទាប់ | ១០ឆ្នាំ | រាល់១០ឆ្នាំ ត្រូវ បូកបន្ថែម ២,៧៥% |
|---|---|---|---|
| **សរុប៤%**<br>កម្មករនិយោជិត២%<br>និយោជក២% | **សរុប៨%**<br>កម្មករនិយោជិត៤%<br>និយោជក៤% | **សរុប១០,៧៥%=៨%+២,៧៥%**<br>កម្មករនិយោជិត៥,៣៧៥%<br>និយោជក៥,៣៧៥% | **សរុប១៣,៥%=១០,៧៥% +២,៧៥%**<br>កម្មករនិយោជិត៦,៧៥%<br>និយោជក៦,៧៥% |

| ៤%(ស្ម័គ្រចិត្ត) | ៨%(ស្ម័គ្រចិត្ត) | ១០,៧៥%(ស្ម័គ្រចិត្ត) | ១០,៧៥% + **២,៧៥%**(ស្ម័គ្រចិត្ត) |
|---|---|---|---|
| ចាប់ផ្តើម២០២១-២៥ | ២០២៦-២០៣០ | ២០៣១-២០៤០ | រាល់១០ឆ្នាំ ត្រូវ បូកបន្ថែម ២,៧៥% |